**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២៣: អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៤ស្ទួននៃអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ( កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បកចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)ចំណុះក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រាមួយ .-**

ត្រូវបានធ្វើការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ស្ទួននៃអនុក្រឹត្យ លេខ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម ដូចតទៅ៖

**មាត្រា២ .- ថ្មី**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) មានបេសកកម្មដូចតទៅ៖

- ធានាគុណភាព សុវត្ថិភាពផលិតផល និងសេវា ព្រមទាំងការពារអ្នកប្រើប្រាស់
- ធានាកិច្ចការពារពាណិជ្ជកម្មប្រកបដោយសមធម៌
- ធានាអនុលោមភាពនៃបណ្តាល័ក្ខខ័ណ្ឌតម្រូវផ្នែកច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ទទួលធ្វើសេវាត្រួតពិនិត្យពាណិជ្ជកម្មជាលក្ខណៈភាគីទី៣
- ជំរុញឱ្យផលិតផលម្ហូបអាហារ ផលិតផលមិនមែនម្ហូបអាហារលក់លើទីផ្សារមានគុណភាព សុវត្ថិភាព ការពារផលប្រយោជន៍អ្នកប្រើប្រាស់
- ធានាការពារការប្រកួតប្រជែងសំដៅឱ្យប្រតិបត្តិករអាជីវកម្មគ្រប់ប្រភេទ តាមគ្រប់វិស័យ ធ្វើការប្រកួតប្រជែងគ្នាប្រកបដោយសមធម៌និងស្មើភាពនិងដើម្បីជម្រុញនិងការពារផលប្រយោជន៍នៃសេដ្ឋកិច្ចទីផ្សារប្រកួតប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .- ថ្មី**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យ ទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) មានភារកិច្ចដូចតទៅ៖

- ផ្តល់សេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូលរួមជាមួយស្ថាប័នគយនិងវិជ្ជាករផ្នែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- ការពារអ្នកប្រើប្រាស់ ធានាគុណភាព សុវត្ថិភាពផលិតផលទំនិញ និងបង្ក្រាបការក្លែងបន្លំ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- រួមចំណែកកសាងផែនការយុទ្ធសាស្ត្រ គោលនយោបាយ ធានាជំរុញនិងការពារផលប្រយោជន៍សេដ្ឋកិច្ចទីផ្សារប្រកួតប្រជែង
- ប្រយុទ្ធប្រឆាំងនឹងសកម្មភាពខុសច្បាប់ទាំងឡាយនៃប្រតិបត្តិករអាជីវកម្មទាំងក្នុងទំនាក់ទំនងខ្សែផ្តេកនិងទាំងក្នុងទំនាក់ទំនងខ្សែរឈរ

- ធ្វើការពិនិត្យសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀងរវាងប្រតិបត្តិករអាជីវកម្មដែលមានឥទ្ធិពលរារាំងរឹតត្បិតឬបង្ខូចការប្រកួតប្រជែងជាសក្តានុពលលើទីផ្សារ
- ធ្វើវិញ្ញាបនបត្រកម្មចំពោះទំនិញនាំចេញ តាមសំណើរបស់អ្នកស្នើសុំ ដើម្បីបំពេញល័ក្ខខ័ណ្ឌតម្រូវនៃប្រទេសនាំចូល
- ត្រួតពិនិត្យភាពអនុលោមតាមស្តង់ដារជាតិ គុណភាព សុវត្ថិភាពផលិតផលទំនិញដែលមានប្រើសញ្ញាស្តង់ដារជាតិ
- សហការត្រួតពិនិត្យជាមុននូវប្រតិវេទន៍នៃផលិតផលទំនិញឬសេវាទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព សុខភាពនៃអ្នកប្រើប្រាស់ ឬផលិតកម្ម ឬពាណិជ្ជកម្មនៃផលិតផលទំនិញ និងសេវាកម្មទាំងនោះដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច
- ត្រួតពិនិត្យផលិតផលទំនិញនិងសេវាក្នុងដំណាក់កាលធ្វើចរាចរណ៍ពាណិជ្ជកម្មលើទីផ្សារ
- គ្រប់គ្រងមន្ទីរពិសោធន៍របស់ក្រសួងពាណិជ្ជកម្ម ដើម្បីវិភាគគុណភាពផលិតផលទំនិញ
- ផ្តល់សេវាត្រួតពិនិត្យលក្ខណៈពាណិជ្ជកម្ម
- ប្រមូលកម្រៃសេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូល និងកម្រៃវិភាគគុណភាពទំនិញ
- ជាលេខាធិការដ្ឋាននៃគណៈកម្មាធិការកូដិចជាតិ
- ទទួលរាប់រងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យប្រកួតប្រជែង
- ជាចំណុចទំនាក់ទំនងសម្រាប់ទទួលនិងផ្តល់ព័ត៌មានពីអនាម័យនិងភូតគាមអនាម័យ
- ជាចំណុចទំនាក់ទំនងផ្តល់ព័ត៌មានអំពីសុវត្ថិភាពម្ហូបអាហារក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការចិន អាស៊ាន
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួនអនុលោមតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របទាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**មាត្រា៤ .- ថ្មី**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) មាននាយកដ្ឋានចំណុះចំនួន ៥(ប្រាំ) នៅថ្នាក់កណ្តាលនិងអង្គភាពថ្នាក់មូលដ្ឋាន ដូចខាងក្រោម៖

ក. ថ្នាក់កណ្តាល(ថ្នាក់គោលនយោបាយ)៖

- នាយកដ្ឋានដោះស្រាយវិវាទនិងគោលនយោបាយទូទៅ
- នាយកដ្ឋានបច្ចេកទេសនិងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់និងបង្ក្រាបការក្លែងបន្លំ
- នាយកដ្ឋានមន្ទីរពិសោធន៍
- នាយកដ្ឋានកិច្ចការប្រកួតប្រជែង

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនអនុលោមតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របទាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ខ. អង្គភាពថ្នាក់មូលដ្ឋាន(ថ្នាក់អនុវត្ត)៖

សាខាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)ថ្នាក់មូលដ្ឋាន រួមមាន៖

- សាខាផែស្ងួត សាខាតំបន់សេដ្ឋកិច្ចពិសេស សាខាអាកាសយានដ្ឋានអន្តរជាតិ សាខាកំពង់ផែអន្តរជាតិ សាខារាជធានី-ខេត្ត
- ប៉ុស្តិ៍ ប៉ុស្តិ៍ផែ ប៉ុស្តិ៍ឃ្លាំងទំនិញ ប៉ុស្តិ៍ស្ថានីយ៍អ្នកដំណើរ ប៉ុស្តិ៍ផែអន្តរជាតិ ប៉ុស្តិ៍អន្តរជាតិ
- មជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត

សាខាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ថ្នាក់មូលដ្ឋាន ដឹកនាំដោយប្រធានសាខាមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននិងអមដោយអនុប្រធានសាខាចំនួន ៣(បី)រូប មានឋានៈស្មើប្រធានការិយាល័យថ្នាក់កណ្តាល។

ប្រធានប៉ុស្តិ៍ ប្រធានមជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត មានឋានៈស្មើប្រធានការិយាល័យថ្នាក់កណ្តាល។

ប្រធាន អនុប្រធានសាខា ប្រធានប៉ុស្តិ៍ និងប្រធានមជ្ឈមណ្ឌលត្រួតពិនិត្យនិងផែស្ងួត ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអនុលោមតាមនីតិវិធីជាធរមាន។

មន្ត្រីរាជការដែលបានតែងតាំងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃអង្គភាពថ្នាក់មូលដ្ឋាននៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)បច្ចុប្បន្ន ត្រូវរក្សាទុកដដែលឬកែសម្រួលឱ្យកាន់មុខតំណែងជាប្រធានប៉ុស្តិ៍ឬប្រធានមជ្ឈមណ្ឌលអនុលោមតាមការកំណត់នៃអនុក្រឹត្យនេះ ដោយមិនអនុញ្ញាតឱ្យមន្ត្រីរាជការកាន់មុខតំណែងអចិន្ត្រៃយ៍ពីរបានឡើយ។

ការរៀបចំនិងការប្រព្រឹត្តទៅថ្នាក់ក្រោមនាយកដ្ឋាននិងអង្គភាពថ្នាក់មូលដ្ឋាននៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

អង្គការលេខរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨ .- ស្ទួន**

នាយកដ្ឋានកិច្ចការប្រកួតប្រជែង មានភារកិច្ចដូចតទៅ៖

- ចូលរួមរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនិងគោលនយោបាយពាក់ព័ន្ធ ដើម្បីធានាការពារការប្រកួតប្រជែងប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច
- សិក្សាស្រាវជ្រាវនិងទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធកិច្ចការប្រកួតប្រជែងទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ
- ស៊ើបអង្កេតនិងស្នើវិធានការអនុវត្តច្បាប់ចំពោះសកម្មភាពទាំងឡាយដែលត្រូវហាមឃាត់ឬមានការរិតត្បិតដល់ការប្រកួតប្រជែង
- វិភាគសន្និដ្ឋានលើអង្គហេតុ អង្គច្បាប់ ហើយរៀបចំនូវសេចក្តីព្រាងសេចក្តីសម្រេច បទបញ្ជានិងសេចក្តីថ្លែងការ ព្រមទាំងការដោះស្រាយវិវាទ ដាក់ជូនអគ្គនាយកដ្ឋាន
- ធ្វើជាតំណាងឱ្យយន្តការដោះស្រាយវិវាទលើករណីពាក់ព័ន្ធក្នុងនីតិវិធីរបស់តុលាការ
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ: ១៤៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៦

**អង្គការលេខរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)**

**អគ្គនាយក**

- លេខាធិការដ្ឋានគណៈកម្មាធិការអន្តរក្រសួងសម្របសម្រួលកិច្ចការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផល និងសេវា "គណៈកម្មាធិការកូដិច (Codex) ជាតិ"
- នាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ
- នាយកដ្ឋានបច្ចេកទេសនិងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ
- នាយកដ្ឋានមន្ទីរពិសោធន៍
- នាយកដ្ឋានកិច្ចការប្រភូតប្រវែង
- អង្គភាពមូលដ្ឋានរួមមាន:
  - សាខា
  - ប៉ុស្តិ៍
  - មជ្ឈមណ្ឌលត្រួតពិនិត្យនិងដែសួត